ជូនលោកអ្នកនៃក្រុមហ៊ុនទទួលបន្ទុកគ្រប់គ្រង

# ចំណុចសម្គាល់សម្រាប់ការជ្រើសរើសក្រុមហ៊ុនបញ្ជូនសិក្ខាកាមនៅបរទេស

ច្បាប់នៃប្រទេសជប៉ុនបានចែងអំពីលក្ខខណ្ឌតម្រូវដែលត្រូវបំពេញសម្រាប់ក្រុមហ៊ុនបញ្ជូនសិក្ខាកាមបរទេសរួចហើយ ប៉ុន្តែក្នុងនាមជាក្រុមហ៊ុនបញ្ជូនសិក្ខាកាមបរទេស មានក្រុមហ៊ុនមួយចំនួនបាននិងកំពុងរៀបចំយន្តការឈានមុខគេ ដើម្បីបំពេញភារកិច្ចរបស់ខ្លួនឱ្យកាន់តែសមស្រប និងបញ្ជូនបេក្ខជនសិក្ខាកាមនៃការហ្វឹកហ្វឺនបច្ចេកទេសដែលមានឆន្ទៈខ្ពស់។ លើកនេះ អង្គភាពកិច្ចការហ្វឹកហ្វឺនជំនាញសម្រាប់ជនបរទេស (អង្គភាព) បានសង្ខេបចំណុចមួយចំនួនសម្រាប់កំណត់អត្តសញ្ញាណក្រុមហ៊ុនបញ្ជូនសិក្ខាកាមដែលកំពុងរៀបចំប្រព័ន្ធគ្រប់គ្រងបែបទំនើបនេះ រួមជាមួយនឹងឧទាហរណ៍ជាក់ស្តែងនៅក្នុងក្រុមហ៊ុនបញ្ជូនសិក្ខាកាមដែលកំពុងអនុវត្តយន្តការនេះ។ យើងខ្ញុំសង្ឃឹមថា ការចងក្រងនេះ នឹងបានជាប្រយោជន៍ដល់លោកអ្នក។

យើងខ្ញុំក៏សូមផ្តល់អនុសាសន៍ដែរថា សូមលោកអ្នកក្រុមហ៊ុនទទួលបន្ទុកគ្រប់គ្រងចែកចាយព័ត៌មាននេះទៅក្នុងចំណោមក្រុមហ៊ុនបញ្ជូនសិក្ខាកាមដូចគ្នាអំពីឧទាហរណ៍នៃក្រុមហ៊ុនបញ្ជូនសិក្ខាកាមដែលទទួលបានការវាយតម្លៃខ្ពស់នេះ។

## ◎ លក្ខខណ្ឌនិងចំណុចសម្គាល់នៃក្រុមហ៊ុនបញ្ជូនសិក្ខាកាមបរទេស

### 1. ក្រុមហ៊ុនបញ្ជូនសិក្ខាកាមដែលមានអាជ្ញាបណ្ណ ឬទទួលបានការណែនាំពីស្ថាប័នសាធារណៈ

☐ 〔ករណីរដ្ឋបញ្ជូនជារដ្ឋដែលបានចុះ MOC （កិច្ចព្រមព្រៀងពីរភាគី）〕

តើក្រុមហ៊ុននោះជា ក្រុមហ៊ុនមានអាជ្ញាបណ្ណ ដែលត្រូវបានផ្សព្វផ្សាយនៅលើគេហទំព័ររបស់អង្គភាពដែរឬទេ?

នេះជាគេហទំព័ររបស់អង្គភាព

✔ សូមពិនិត្យបញ្ជាក់នៅក្នុងបញ្ជីនៃក្រុមហ៊ុនបញ្ជូនសិក្ខាកាមបរទេសដែលត្រូវបានទទួលស្គាល់ដោយរដ្ឋាភិបាលបរទេសនៅលើគេហទំព័ររបស់អង្គភាព។

☐ 〔ករណីរដ្ឋបញ្ជូនជារដ្ឋដែលបានចុះ MOC〕

តើក្រុមហ៊ុននោះមានលិខិតណែនាំពីស្ថាប័នសាធារណៈនៅប្រទេសឬតំបន់របស់ក្រុមហ៊ុននោះឬទេ?

✔ សូមទាក់ទងទៅអ្នកទទួលខុសត្រូវនៅក្រុមហ៊ុនបញ្ជូនសិក្ខាកាមនោះ និងបញ្ជាក់មើលឯកសារចម្លង។

### 2. មានការជ្រើសរើស និងការបញ្ជូនសិក្ខាកាមដែលបានយល់អំពីគោលបំណងនៃប្រព័ន្ធ

☐ តើក្រុមហ៊ុនបញ្ជូនសិក្ខាកាមនោះប្រើមធ្យោបាយ/ដំណើរការបែបណាខ្លះដើម្បីប្រកាស និង ជ្រើសរើសបេក្ខជន?

✔ សូមពិនិត្យមើលការផ្សព្វផ្សាយជ្រើសរើសសិក្ខាកាមរបស់ក្រុមហ៊ុននោះនៅលើប្រព័ន្ធទំនាក់ទំនងសង្គម (Facebook, TikTok, Zalo ជាដើម) ឬគេហទំព័ររបស់ក្រុមហ៊ុន ដើម្បីបញ្ជាក់មើលថាតើក្រុមហ៊ុននោះបានពន្យល់សមស្របអំពីអត្ថន័យ និងប្រាក់ឈ្នួលនៃការងារ លំហូរនៃនីតិវិធីរហូតដល់ពេលចាប់ផ្តើមអនុវត្តការងារជាសិក្ខាកាមជាដើម។

“ឈ្មោះក្រុមហ៊ុនបញ្ជូន” ស្វែងរក

✔ បញ្ជាក់ដោយផ្ទាល់ជាមួយក្រុមហ៊ុនបញ្ជូនសិក្ខាកាមនោះ។

Organization for Technical Intern Training

# ចំណុចសម្គាល់សម្រាប់ការជ្រើសរើសក្រុមហ៊ុនបញ្ជូនសិក្ខាកាមនៅបរទេស

☐ តើក្រុមហ៊ុនបញ្ជូនសិក្ខាកាមបានពន្យល់ណែនាំអំពីគោលបំណងនៃកម្មវិធីហ្វឹកហ្វឺនសិក្ខាកាមដូចម្តេចខ្លះនៅពេលប្រកាសជ្រើសរើស?

☐ នៅពេលជ្រើសរើសសិក្ខាកាម តើក្រុមហ៊ុនធានាចំពោះបេក្ខជនសិក្ខាកាមហ្វឹកហ្វឺនជំនាញដែលមានឆន្ទៈខ្ពស់ក្នុងការបង្ហាលទ្ធផលបន្ទាប់ពីត្រឡប់ទៅប្រទេសកំណើតរបស់ពួកគេដោយរបៀបណា?

☐ តើក្រុមហ៊ុនបញ្ជូនសិក្ខាកាមពន្យល់អំពីលក្ខខណ្ឌការងារ (កន្លែងធ្វើការ ម៉ោងធ្វើការ ប្រាក់ឈ្នួល (រួមទាំងការកាត់ពន្ធ និធានារ៉ាប់រងសង្គម) ខ្លឹមសារការងារ ជីវិតនៅ ប្រទេសជប៉ុន ជាដើម) និងហានិភ័យដែលកើតឡើងដោយសារការរត់ពីទីតាំអនុវត្ត ការហ្វឹកហ្វឺននៅក្នុងប្រទេសជប៉ុន បែបណាខ្លះ?

☐ តើបេក្ខជនសិក្ខាកាមហ្វឹកហ្វឺនជំនាញពិតជាយល់ច្បាស់អំពីខ្លឹមសារខាងលើដែរឬទេ?

✔ ស្តាប់ការពន្យល់ណែនាំដែលក្រុមហ៊ុនបញ្ជូនសិក្ខាកាមបានពន្យល់ចំពោះបេក្ខជនសិក្ខាកាមហ្វឹកហ្វឺនជំនាញ។

✔ បញ្ជាក់ជាមួយបេក្ខជនសិក្ខាកាមហ្វឹកហ្វឺនជំនាញថាតើគាត់ពិតជាបានយល់ច្បាស់អំពីគោលបំណងនៃកម្មវិធីហ្វឹកហ្វឺនសម្រាប់សិក្ខាកាមហ្វឹកហ្វឺនជំនាញមែនឬទេ។

✔ សាកសួរបេក្ខជនសិក្ខាកាមហ្វឹកហ្វឺនជំនាញដោយផ្ទាស់ថាតើពួកគាត់មានផែនការការងារបន្ទាប់ពីត្រឡប់ទៅ ប្រទេសកំណើតវិញ។

✔ បញ្ជាក់ជាមួយបេក្ខជនសិក្ខាកាមហ្វឹកហ្វឺនជំនាញដោយផ្ទាល់ថាតើគាត់យល់ច្បាស់ពីលក្ខខណ្ឌការងារ និងហា និភ័យដែលកើតពីការរត់ពីទីកន្លែងអនុវត្តការហ្វឹកហ្វឺនដែរឬទេ។

☐ តើក្រុមហ៊ុនបញ្ជូនសិក្ខាកាមផ្តល់ព័ត៌មានត្រូវគ្នាជាមួយបេក្ខជនសិក្ខាកាមហ្វឹកហ្វឺនជំនាញ យ៉ាងដូចម្តេច?

✔ បញ្ជាក់មើលថាតើក្រុមហ៊ុនបញ្ជូននោះ ជាក្រុមហ៊ុនដែលទទួលយកភ្លាមៗនូវខ្លឹមសារនៃវគ្គហ្វឹកហ្វឺនសិក្ខាកាមហ្វឹកហ្វឺនជំនាញដោយមិនគិតពីប្រភេទការងារ កាតព្វកិច្ចការងារ ឬប្រាក់ឈ្នួលឬទេ និងថាតើក្រុមហ៊ុនបានផ្គូផ្គងការងារដោយយកចិត្តទុកដាក់ពិចារណាលើគោលបំណងនិងកាលៈទេសៈរបស់បេក្ខជនសិក្ខាកាមហ្វឹកហ្វឺនជំនាញជាមួយនិងកន្លែងហ្វឹកហ្វឺនដែលឬទេ។

# ចំណុចសម្គាល់សម្រាប់ការជ្រើសរើសក្រុមហ៊ុនបញ្ជូនសិក្ខាកាមនៅបរទេស

☐ តើបេក្ខជនសិក្ខាកាមហ្វឹកហ្វឺនជំនាញត្រូវបានដាក់បន្ទុកតាមរយៈការបង្កើនបន្ទុកចំណាយរបស់បេក្ខជនសិក្ខាកាមហ្វឹកហ្វឺនជំនាញ ដូចជាការអន្តរាគមន៍ពីមេខ្យល់ដែលមានគំនិតអាក្រក់ដែរឬទេ?

✔ បញ្ជាក់ថាតើមានការអន្តរាគមន៍ពីមេខ្យល់ដែលមានគំនិតអាក្រក់ឬទេ តាមរយៈការសួរទៅក្រុមហ៊ុនបញ្ជូនថា "នៅពេលជ្រើសរើសសិក្ខាកាមហ្វឹកហ្វឺនជំនាញ តើមេខ្យល់ទារប្រាក់កំរៃពីសិក្ខាកាមហ្វឹកហ្វឺនជំនាញច្រើនឬទេ?“

✔ បញ្ជាក់ថាតើមានការអន្តរាគមន៍ពីមេខ្យល់ដែលមានគំនិតអាក្រក់ឬទេ តាមរយៈការសួរបេក្ខជនសិក្ខាកាមហ្វឹកហ្វឺនជំនាញថា "តើអ្នកបានពឹងពាក់ និងបង់ប្រាក់ច្រើនទៅមេខ្យល់ឬទេនៅពេលចុះឈ្មោះជាមួយក្រុមហ៊ុនបញ្ជូនសិក្ខាកាម ” ?

(យោង)

MOC រវាងរដ្ឋាភិបាលជប៉ុន និងវៀតណាមបានហាមប្រាមក្រុមហ៊ុនបញ្ជូនសិក្ខាកាមមិនឱ្យមានមេខ្យល់ធ្វើអន្តរាគមន៍។

**ឧទាហរណ៍នៃយន្តការរបស់ក្រុមហ៊ុនបញ្ជូន**

〔ឧទាហរណ៍ទី 1〕

ក្រុមហ៊ុនបានរៀបចំកម្មវិធីពន្យល់អំពីការជ្រើសរើសសិក្ខាកាមជារៀងរាល់សប្តាហ៍ ហើយអ្នកចូលរួមទាំងអស់ត្រូវបានកំណត់អោយមានអ្នកចាំប្រឹក្សាជាមួយ។ បន្ទាប់ពីអ្នកចូលរួមទាំងអស់បានដោះស្រាយរាល់ចម្ងល់រួចហើយ បេក្ខជនឈ្មោះដោយស្ម័គ្រចិត្ត។ លើសពីនេះ នៅពេលជ្រើសរើសបេក្ខជនសិក្ខាកាមហ្វឹកហ្វឺនជំនាញ ក្រុមហ៊ុនបញ្ជូនបង្កើតគោលការណ៍និងការអនុវត្តនីតិវីធីនៃក្រុមហ៊ុនរបស់ពួកគេដូចខាងក្រោម ហើយមានតែអ្នកដែលយល់ព្រមនឹងគោលការណ៍និងការអនុវត្តនីតិវិធីនោះប៉ុណ្ណោះដែលនឹងត្រូវ ជ្រើសរើស។

<u>គោលការណ៍ក្រុមហ៊ុនក្នុងការអនុវត្តនីតិវិធីការជ្រើសរើសបេក្ខជន</u>

បេក្ខជនត្រូវរៀនភាសាជប៉ុន រៀនអំពីសីលធម៌ធុរកិច្ច ស្វែងយល់អំពីផែនការការងារ ជាដើម នៅស្ថាប័នត្រៀម (*) រយៈពេលប្រហែលមួយឆ្នាំ។ ក្នុងអំឡុងពេលនោះ សិស្សនឹងត្រូវបានផ្គូផ្គងជាមួយក្រុមហ៊ុនអនុវត្ត ការហ្វឹកហ្វឺនដែលសមស្រប។

# ចំណុចសម្គាល់សម្រាប់ការជ្រើសរើសក្រុមហ៊ុនបញ្ជូនសិក្ខាកាមនៅបរទេស

## ឧទាហរណ៍នៃយន្តការរបស់ក្រុមហ៊ុនបញ្ជូន

〔ឧទាហរណ៍ទី 2 〕

រដ្ឋបញ្ជូនបានសហការរៀបចំសាលាបណ្តុះបណ្តាលវិជ្ជាជីវៈជាតិជាស្ថាប័នត្រៀម (*)។ កម្មវិធីសិក្សារបស់សាលាបណ្តុះបណ្តាលនេះ ក្រៅពីត្រូវបានបង្កើតឡើងដោយផ្អែកលើលក្ខណៈបច្ចេកទេសរបស់ប្រទេសជប៉ុន។ នៅតាមក្រុមហ៊ុនបញ្ជូនសិក្ខាកាមក៏បង្កើតអត្ថបទ និងវីដេអូអប់រំតាមប្រព័ន្ធអេឡិចត្រូនិក ដោយផ្អែកលើលក្ខណៈបច្ចេកទេសដូចគ្នា ហើយដាក់ជា សម្ភារៈសិក្សាឱ្យសិស្សនៅក្នុងសាលាហ្វឹកហ្វឺននោះសិក្សាដោយខ្លួនឯងបាន។ និយាយរួម បេក្ខជនសិក្ខាកាមហ្វឹកហ្វឺនជំនាញទាំងនោះ ត្រូវបានជ្រើសរើសពីក្នុងបេក្ខជនដែលមានចំណាប់អារម្មណ៍ខ្លាំងចំពោះប្រទេសជប៉ុន ហើយចង់ទទួលបានចំណេះដឹង និងជំនាញរបស់ប្រទេសជប៉ុនបន្ថែមទៀត ហេតុនេះក្រុមហ៊ុនអាចដាក់បន្ទុកបាននូវបេក្ខជនសិក្ខាកាមហ្វឹកហ្វឺនជំនាញដែលមានឆន្ទៈខ្ពស់បាន។

* ស្ថាប័នត្រៀម ： សំដៅដល់អង្គភាពបរទេសដែលចូលរួមក្នុងការរៀបចំនៅក្រៅប្រទេសរបស់បុគ្គលដែលមានបំណងចង់ក្លាយជាសិក្ខាកាមហ្វឹកហ្វឺនជំនាញ ឧទាហរណ៍ដូចជាក្រុមហ៊ុនផ្សេងៗ រួមមានក្រុមហ៊ុនដែលបុគ្គលដែលមានបំណងចង់ក្លាយជាសិក្ខាកាមហ្វឹកហ្វឺនជំនាញធ្លាប់ធ្វើការ ក្រុមហ៊ុននៃសាលាភាសាជប៉ុនដែលទទួលអ្នកដាក់ពាក្យក្នុងទ្រង់ទ្រាយទូលំទូលាយចំពោះអ្នកដែលចង់ក្លាយជាសិក្ខាកាមហ្វឹកហ្វឺនជំនាញ ឬក្រុមហ៊ុនរត់ការនីតិវិធីស្នើសុំលិខិតឆ្លងដែន និងទិដ្ឋាការជាដើម។

〔ឧទាហរណ៍ទី 3 〕

ការសម្ភាសន៍ជ្រើសរើសបេក្ខជនសិក្ខាកាមហ្វឹកហ្វឺនជំនាញ ជាទូទៅត្រូវបានធ្វើឡើងដោយក្រុមហ៊ុនទទួលបន្ទុកគ្រប់គ្រង ប៉ុន្តែក៏មានករណីខ្លះ ភាគីក្រុមហ៊ុនអនុវត្តការហ្វឹកហ្វឺនជាអ្នកទៅសម្ភាសន៍ដោយផ្ទាល់នៅប្រទេសដែលបញ្ជូនសិក្ខាកាមនោះមកតែម្តង។ ជាលទ្ធផល ក្រុមហ៊ុនអនុវត្តការហ្វឹកហ្វឺនអាចដឹងជាមុនអំពីស្ថានភាពបុគ្គលរបស់បេក្ខជនសិក្ខាកាមហ្វឹកហ្វឺនជំនាញយ៉ាងលម្អិត ដូចជាបុគ្គលិកលក្ខណៈ និងចំណូលចិត្តរបស់ពួកគេ ហើយអាចធ្វើការជ្រើសរើសដោយផ្អែកលើព័ត៌មានទាំងនោះ។ លើសពីនេះ ការធ្វើដូចនេះ នឹងធ្វើអោយក្រុមហ៊ុនអនុវត្តការហ្វឹកហ្វឺន និងបេក្ខជនសិក្ខាកាមបច្ចេកទេស មានទំនួលខុសត្រូវ និងទំនុកចិត្តរវាងគ្នានិងគ្នាទៅវិញទៅមក ដោយសារក្រុមហ៊ុនយល់ថា “សិក្ខាកាមហ្វឹកហ្វឺនជំនាញដែលខ្លួនជាអ្នករើសមក” ហើយសិក្ខាកាមហ្វឹកហ្វឺនជំនាញយល់ថា “ខ្លួនត្រូវបានជ្រើសរើសដោយក្រុមហ៊ុនអនុវត្តការហ្វឹកហ្វឺន”។

ម្យ៉ាងទៀត អ្នកអនុវត្តការហ្វឹកហ្វឺនមានកិច្ចសម្ភាសន៍ជាមួយក្រុមគ្រួសាររបស់បេក្ខជនសិក្ខាកាមហ្វឹកហ្វឺនជំនាញ មុននឹង  សម្រេចចិត្តទទួលយកសិក្ខាកាម។ ក្រុមគ្រួសាររបស់បេក្ខជនសិក្ខាកាមហ្វឹកហ្វឺនជំនាញអាចបញ្ជូនសិក្ខាកាមហ្វឹកហ្វឺនជំនាញទៅប្រទេសជប៉ុនដោយគ្មានក្តីបារម្ភ តាមរយៈការជួបជាមួយក្រុមហ៊ុនអនុវត្តការហ្វឹកហ្វឺន ហើយការធ្វើបែបនេះ បានកាត់បន្ថយបញ្ហាជាច្រើនដូចជាការរត់ជាដើម។

〔ឧទាហរណ៍ទី 4 〕

តាមរយៈការប្រើសាលាបណ្តុះបណ្តាលវិជ្ជាជីវៈជាច្រើនដែលស្ថិតក្រោមយុត្តាធិការរបស់រដ្ឋាភិបាលនៃប្រទេសបញ្ជូនធ្វើជា ស្ថាប័នត្រៀម និងជ្រើសរើសបេក្ខជនសិក្ខាកាមហ្វឹកហ្វឺនជំនាញដោយផ្ទាល់ពីនិស្សិតដែលបានបញ្ចប់ការសិក្សានៅសាលា ទាំងនេះ ហើយយើងក៏នឹងអាចទប់ស្កាត់ការអន្តរាគមន៍របសមេខ្យល់និងការក្លែងបន្លំប្រវត្តិការងារ និងការអប់រំផងដែរ។

# ចំណុចសម្គាល់សម្រាប់ការជ្រើសរើសក្រុមហ៊ុនបញ្ជូនសិក្ខាកាមនៅបរទេស

**3. លក្ខណៈវិនិច្ឆ័យនៃការគណនាថ្លៃឈ្នួល និងការចំណាយផ្សេងៗដែលត្រូវប្រមូលពីបេក្ខជនសិក្ខាកាមហ្វឹកហ្វឺនជំនាញ គួរត្រូវកំណត់អោយបានច្បាស់លាស់ និងបង្ហាញជាសាធារណៈ ព្រមទាំងពន្យល់បង្ហាញអោយបានច្បាស់ដល់បេក្ខជនសិក្ខាកាមហ្វឹកហ្វឺនជំនាញ។**

☐ តើស្តង់ដានៃការគណនាការចំណាយមានទម្រង់បែបណា? តើមានអ្វីមិនច្បាស់លាស់អំពីរបៀបគណនានេះឬទេ?

✔ ប្រសិនបើមានចំណុចមិនច្បាស់លាស់ទាក់ទងនឹងស្តង់ដានៃការគណនា ឬលក្ខខណ្ឌនៃការទូទាត់ សូមស្នើសុំក្រុមហ៊ុនបញ្ជូនអោយធ្វើការពន្យល់។

☐ តើក្រុមហ៊ុនបញ្ជូនបានចាត់តាំងផ្សព្វផ្សាយជាសាធារណៈអំពីស្តង់ដានៃការគណនាចំណាយយ៉ាងដូចម្តេច ហើយតើសិក្ខាកាមហ្វឹកហ្វឺនជំនាញយល់យ៉ាងណាដែរ?

✔ សូមបញ្ជាក់វិធីសាស្ត្រ និងខ្លឹមសារនៃការផ្សព្វផ្សាយដោយក្រុមហ៊ុនបញ្ជូន។(ការចែកខិតប័ណ្ណ ការបោះផ្សាយខិតប័ណ្ណជ្រើសរើសបុគ្គលិក ការបង្ហោះតាមអ៊ីនធឺណេត ជាដើម។)

※ លោកអ្នកអាចប្រើកម្មវិធីបកប្រែដោយស្វ័យប្រវត្តិតាមអ៊ីនធឺណេតដើម្បីចូលមើលគេហទំព័រជាភាសារបស់ ប្រទេសនីមួយៗ។

✔ សូមបញ្ជាក់ជាមួយសិក្ខាកាមហ្វឹកហ្វឺនជំនាញ អំពីការទំនាក់ទំនងជាមួយក្រុមហ៊ុនបញ្ជូនទាក់ទងនឹងការ ចំណាយ។

☐ តើអ្នកបានប្រមូលថ្លៃសេវាពីសិក្ខាកាមហ្វឹកហ្វឺនជំនាញវៀតណាមដែលកំពុងផ្លាស់ប្តូរទៅជា “សិក្ខាកាមហ្វឹកហ្វឺនជំនាញលេខ 3 (ខ)" ឬទេ? (ប្រសិនបើគ្មានការផ្លាស់ប្តូរក្រុមហ៊ុនបញ្ជូន និងក្រុមហ៊ុនទទួលបន្ទុកគ្រប់គ្រង)

✔ សូមសួរសិក្ខាកាមហ្វឹកហ្វឺនជំនាញវៀតណាមថា "តើមានការប្រមូលថ្លៃសេវាពីក្រុមហ៊ុនបញ្ជូនដែរឬទេ? នៅពេលមានការផ្លាស់ប្តូរទៅជាសិក្ខាកាមហ្វឹកហ្វឺនជំនាញលេខ 3 (ខ)“។

(យោង)

យោងតាមបទប្បញ្ញត្តិរបស់រដ្ឋាភិបាលវៀតណាម នៅពេលផ្លាស់ប្តូរពីការហ្វឹកហ្វឺនសិក្ខាកាមហ្វឹកហ្វឺនជំនាញពីលេខ 2 ទៅលេខ 3 ប្រសិនបើគ្មានការផ្លាស់ប្តូរក្រុមហ៊ុនទទួលបន្ទុកគ្រប់គ្រង និងក្រុមហ៊ុនបញ្ជូនទេ ក្រុមហ៊ុនបញ្ជូនមិនអាច ប្រមូលថ្លៃសេវាពីសិក្ខាកាមហ្វឹកហ្វឺនជំនាញបានទេ។

# ចំណុចសម្គាល់សម្រាប់ការជ្រើសរើសក្រុមហ៊ុនបញ្ជូនសិក្ខាកាមនៅបរទេស

## ឧទាហរណ៍នៃយន្តការរបស់ក្រុមហ៊ុនបញ្ជូន

〔ឧទាហរណ៍ទី 1〕

ក្រុមហ៊ុនមួយចំនួនកំពុងធ្វើការដើម្បីកាត់បន្ថយបន្ទុកចំណាយរបស់បេក្ខជនសិក្ខាកាមហ្វឹកហ្វឺនជំនាញ ដោយធ្វើឱ្យការចំណាយទាំងអស់ក្រៅពីអាហារដោយមិនគិតថ្លៃ មុនពេលពួកគេឆ្លងកាត់ការសម្ភាសន៍ជ្រើសរើសបុគ្គលិក។ លើសពីនេះ ដូចដែលបានបង្ហាញខាងក្រោម ក្រុមហ៊ុនធ្វើការផ្សព្វផ្សាយថ្លៃសេវា និងការចំណាយផ្សេងទៀតនៅលើគេហទំព័ររបស់ខ្លួន ដើម្បីធានាបាននូវតម្លាភាព។

គោរពតាមថ្លៃសេវាកំណត់ដោយច្បាប់។ ដាច់ខាតមិនមានការចំណាយសម្រាប់ការធ្វើដំណើរក្រៅផ្លូវការដែលត្រូវបានផ្សព្វផ្សាយនៅប្រទេស ជប៉ុន។ គ្មានការបែងចែកថ្លៃសេវាតាមប្រភេទការងារ។

**“ការកំណត់អំពីសោហ៊ុយចំណាយសម្រាប់ធ្វើដំណើរទៅប្រទេសជប៉ុនរបស់ក្រុមហ៊ុនយើងខ្ញុំ”**

**KHR(　　　　　　　យ៉េន)**

◆ថ្លៃសេវា ··························· KHR(···························យ៉េន)

◆ថ្លៃអប់រំ និងស្នាក់នៅ ··························· KHR(···························យ៉េន)

◆ថ្លៃស្នាក់នៅ គ្រប់គ្រង និងជួសជុល ··························· KHR(···························យ៉េន)

ថ្លៃសេវាខាងលើត្រូវអនុវត្តដូចគ្នាដោយមិនគិតពីពេលវេលាចាប់ពីពេលជាប់ការសម្ភាសន៍រហូតដល់ពេលចេញដំណើរទៅប្រទេសជប៉ុន។ និយាយរួម

ទោះបីជាពេលរង់ចាំពីពេលជាប់សម្ភាសន៍រហូតដល់ពេលចេញដំណើរទៅប្រទេសជប៉ុនត្រូវចំណាយពេល ៤ខែក៏ដោយ កន្លះឆ្នាំក៏ដោយ ១ឆ្នាំក៏ដោយ សោហ៊ុយចំណាយត្រូវគិតដដែល។

【យោង】

◇ សោហ៊ុយចំណាយខាងលើ ជាបន្ទុករបស់សិក្ខាកាមហ្វឹកហ្វឺនជំនាញប្រភេទការងារ៣ឆ្នាំ។

◇ ថ្លៃសេវាសរុប គឺស្មើគ្នា សម្រាប់គ្រប់ប្រភេទការងារ ភេទ អាយុ និងរយៈពេលស្នាក់នៅ។

◇ ថ្លៃអប់រំ និងស្នាក់នៅ ត្រូវបូករួមបញ្ចូលទាំងថ្លៃរៀន ស្នាក់នៅ ទឹកភ្លើង ឯកសណ្ឋាន សៀវភៅសិក្សា(minano nihongo សៀវភៅបោះពុម្ពដើម) ពិនិត្យសុខភាព ថ្លៃទិដ្ឋាការ ជាដើម គិតចាប់ពីថ្ងៃចូលសាលារហូតដល់ថ្ងៃចេញដំណើរទៅប្រទេសជប៉ុន។

◇ ថ្លៃស្នាក់នៅ គ្រប់គ្រង និងជួសជុល សំដៅលើថ្លៃប្រើប្រាស់ ថែរក្សា ជួសជុលរបស់របរសម្រាប់ប្រើប្រាស់ដែលបានរៀបចំជូន មានដូចជាម៉ាស៊ីនត្រជាក់ ផ្ទះបាយ ទូទឹកកក ម៉ាស៊ីនបោកខោអាវជាដើម។

◇ 1JPY=30KHR

(សរសេរដោយមិនបញ្ជាក់តម្លៃនៅទីនេះ)

## 4． បន្ទាប់ពីសិក្ខាកាមហ្វឹកហ្វឺនជំនាញត្រឡប់ទៅប្រទេសកំណើតវិញ ក្រុមហ៊ុនផ្ដល់ការគាំទ្រដូចជាការស្វែងរកការងារធ្វើ ដើម្បីពួកគេអាចប្រើប្រាស់ជំនាញដែលពួកគេទទួលបានត្រឹមត្រូវ។

☐ តើមានការផ្ដល់ប្រឹក្សាការងារដល់សិក្ខាកាមហ្វឹកហ្វឺនជំនាញមុនពេលពួកគេត្រឡប់ទៅប្រទេសកំណើត ដែរឬទេ？

✔ សូមពិនិត្យមើលការពិគ្រោះយោបល់ដែលក្រុមហ៊ុនបញ្ជូនបានទទួលពីសិក្ខាកាមហ្វឹកហ្វឺនជំនាញនាពេល កន្លងមក និងការឆ្លើយតបចំពោះពួកគេ។

# ចំណុចសម្គាល់សម្រាប់ការជ្រើសរើសក្រុមហ៊ុនបញ្ជូនសិក្ខាកាមនៅបរទេស

☐ តើក្រុមហ៊ុនមានការសម្របសម្រួលជាមួយកន្លែងការងារនានា ឬកន្លែងការងារដែលអាចសម្របសម្រួលស្ថានភាពបច្ចុប្បន្ន ឬវិធីគាំពាផ្សេងទៀតសម្រាប់សិក្ខាកាមហ្វឹកហ្វឺនជំនាញបន្ទាប់ពីត្រឡប់ទៅផ្ទះវិញឬទេ?

**ឧទាហរណ៍នៃយន្តការរបស់ក្រុមហ៊ុនបញ្ជូន**

〔ឧទាហរណ៍ទី 1〕

ក្រៅពីការទទួលប្រឹក្សាអំពីការងារនាពេលត្រឡប់ទៅប្រទេសកំណើតវិញ ដោយការរៀបចំអោយមានការធ្វើបទសម្ភាសន៍តាមអ៊ីនធឺណេតជាមួយសិក្ខាកាមហ្វឹកហ្វឺនជំនាញ សិក្ខាកាមហ្វឹកហ្វឺនជំនាញដែលបានត្រឡប់ទៅប្រទេសកំណើតវិញ ត្រូវបានក្រុមហ៊ុនណែនាំវគ្គហ្វឹកហ្វឺនគាំពារការរកស្វែងរកការងារនៅក្រុមហ៊ុនក្នុងវិស័យដែលពួកគេចង់ធ្វើ។

〔ឧទាហរណ៍ទី 2〕

ក្រុមហ៊ុនគាំទ្រដល់សិក្ខាកាមហ្វឹកហ្វឺនជំនាញដែលចង់បើកអាជីវកម្មផ្ទាល់ខ្លួនដោយប្រើសមត្ថភាព ចំណេះដឹង និងជំនាញដែលទទួលបានតាមរយៈការហ្វឹកហ្វឺននៅប្រទេសជប៉ុន។ ឧទាហរណ៍ សម្រាប់សិក្ខាកាមហ្វឹកហ្វឺនជំនាញដែលចង់បើកការាសថែទាំរថយន្ត ក្រុមហ៊ុនដែលជាក្រុមនៃក្រុមហ៊ុនបញ្ជូន ជាអ្នកការផ្តល់ដើមទុនសម្រាប់ការចាប់ផ្តើម ការជួលរថយន្ត ការធានារ៉ាប់រងរថយន្តជាដើម ដើម្បីអោយសិក្ខាកាមទទួលបាននូវក្តីសុបិនរបស់ខ្លួននៅក្រោយពេលត្រឡប់ទៅប្រទេសកំណើតវិញ។

**5. ក្រុមហ៊ុនបញ្ជូន សហការជាមួយនឹងការស្នង់មតិដែលធ្វើ ឡើងដោយភាគីជប៉ុនទាក់ទងនឹងស្ថានភាពនៃការផ្ទេរជំនាញជាដើមតាមរយៈសិក្ខាកាមហ្វឹកហ្វឺនជំនាញដែលបានត្រឡប់ទៅប្រទេសកំណើតរបស់ពួកគេវិញ ឬការស្នើសុំផ្សេងទៀតធ្វើឡើងដោយភាគីជប៉ុន។**

**6. ក្រុមហ៊ុនបញ្ជូន ឬអភិបាលរបស់ក្រុមហ៊ុននោះ មិនត្រូវជាបុគ្គលដែលធ្លាប់ត្រូវបានកាត់ទោសដាក់ពន្ធនាគារ ឬដាក់ទោសធ្ងន់ជាងនេះក្នុងរយៈពេលប្រាំឆ្នាំចុងក្រោយឡើយ គិតចាប់តាំងពីថ្ងៃដែលការកាត់ទោសបានបញ្ចប់ ឬចប់ការអនុវត្តទោស។**

**7. ធ្វើអាជីវកម្មស្របតាមច្បាប់នៃប្រទេសបញ្ជូន**

✔ សូមប្រមូលព័ត៌មាន និងពិនិត្យមើលថាតើក្រុមហ៊ុននោះយល់អំពីច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធនៅក្នុង ប្រទេសជប៉ុនដែរឬទេ។

# ចំណុចសម្គាល់សម្រាប់ការជ្រើសរើសក្រុមហ៊ុនបញ្ជូនសិក្ខាកាមនៅបរទេស

## 8. ក្រុមហ៊ុនបញ្ជូន ឬបុគ្គលិកក្រុមហ៊ុននោះមិនធ្លាប់ធ្វើសកម្មភាពទាំងនេះក្នុងអំឡុងពេល៥ឆ្នាំ ចុងក្រោយនេះ

- សកម្មភាពនៃការគ្រប់គ្រងប្រាក់ និងទ្រព្យសម្បត្តិផ្សេងទៀតរបស់សិក្ខាកាមហ្វឹកហ្វឺនជំនាញ និងបុគ្គលពាក់ព័ន្ធនឹងសិក្ខាកាមហ្វឹកហ្វឺនជំនាញ (*) ដោយការប្រមូលប្រាក់ធានារ៉ាប់រងជាដើម។
- សកម្មភាពនៃការសន្យាបង់ប្រាក់ ឬទ្រព្យសម្បត្តិផ្សេងទៀត ក្នុងករណីមិនបំពេញកិច្ចសន្យាទាក់ទងនឹងការ ហ្វឹកហ្វឺនបច្ចេកទេស
- សកម្មភាពរំលោភសិទ្ធិមនុស្សជាដើម លើសិក្ខាកាមហ្វឹកហ្វឺនជំនាញ។
- សកម្មភាពដូចជាការក្លែងបន្លំឯកសារទាក់ទងនឹងការហ្វឹកហ្វឺនសិក្ខាកាមហ្វឹកហ្វឺនជំនាញ ក្នុងគោលបំណងទទួលបានការអនុញ្ញាតក្នុងការអនុវត្តការហ្វឹកហ្វឺនសិក្ខាកាមហ្វឹកហ្វឺនជំនាញជាដើម។

* បុគ្គលទាក់ទងនឹងសិក្ខាកាមហ្វឹកហ្វឺនជំនាញ៖ សិក្ខាកាមហ្វឹកហ្វឺនជំនាញ ឬ ប្តីប្រពន្ធ សាច់ញាតិផ្ទាល់ ឬ សាច់ញាតិដែលនៅផ្ទះជាមួយគ្នា និងអ្នកផ្សេងទៀតដែលមានទំនាក់ទំនងសង្គមជិតស្និទ្ធជាមួយសិក្ខាកាម។

☐ (ពិនិត្យកិច្ចសន្យាជាក់ស្តែងជាមួយសិក្ខាកាមហ្វឹកហ្វឺនជំនាញ) ថាតើមានប្រយោគណាដែលនាំឲ្យខូចប្រយោជន៍ដល់សិក្ខាកាមហ្វឹកហ្វឺនជំនាញឬទេ?

☐ តើសិក្ខាកាមហ្វឹកហ្វឺនជំនាញបានបញ្ជាក់ និងយល់ពីខ្លឹមសារនៃឯកសារដែលបង្កើតដោយក្រុមហ៊ុនបញ្ជូន ដូចជាប្រវត្តិរូបសង្ខេបរបស់សិក្ខាកាមហ្វឹកហ្វឺនជំនាញជាដើម មុននឹងចុះហត្ថលេខាដែរឬទេ?

✔ សូមពិនិត្យមើលដំណើរការនៃការរៀបចំឯកសាររបស់ក្រុមហ៊ុនបញ្ជូន

✔ បញ្ជាក់ជាមួយសិក្ខាកាមហ្វឹកហ្វឺនជំនាញថាតើពួកគេបានទទួលការពន្យល់គ្រប់គ្រាន់ពីក្រុមហ៊ុនបញ្ជូនឬអត់ទាក់ទងនឹងឯកសារដែលរៀបចំដោយក្រុមហ៊ុនបញ្ជូន ហើយថាតើពួកគេបានយល់ខ្លឹមសារ មុននិងចុះហត្ថលេខាឬទេ។

※ លើសពីនេះ ប្រសិនបើក្រុមហ៊ុនទទួលបន្ទុកគ្រប់គ្រងបានសន្យាជាមួយក្រុមហ៊ុនបញ្ជូនដើម្បីទទួលបានប្រាក់ចំណេញមិនសមស្រប ដូចជាកិច្ចសន្យាសំណងការខូចខាត ឬ សងប្រាក់ត្រឡប់វិញក្នុងករណីមិនអនុវត្តកិច្ចសន្យា នោះ អាចនឹងមានការដកហូតលិខិតអនុញ្ញាតអោយគ្រប់គ្រងចំពោះក្រុមហ៊ុនទទួលបន្ទុកគ្រប់គ្រង។

# ចំណុចសម្គាល់សម្រាប់ការជ្រើសរើសក្រុមហ៊ុនបញ្ជូនសិក្ខាកាមនៅបរទេស

**9． បញ្ជាក់ជាមួយសិក្ខាកាមហ្វឹកហ្វឺនជំនាញទាក់ទងនឹងរឿងលុយកាក់ និងទ្រព្យសម្បត្តិផ្សេងៗ មិនត្រូវមានការគ្រប់គ្រងដោយការប្រមូលប្រាក់ធានារ៉ាប់រងជាដើមឡើយ និងមិនត្រូវសន្យា បង់ប្រាក់ និងទ្រព្យសម្បត្តិផ្សេងទៀតនៅក្នុងករណីមិនបានអនុវត្តតាមកិច្ចសន្យានៅក្នុងរឿង ហ្វឹកហ្វឺនបច្ចេកទេសជាក់ស្តែងឡើយ។**

✔ ក្រុមហ៊ុនបញ្ជូនត្រូវបញ្ជាក់ថាតើមានការបញ្ជាក់ដូចខាងលើនេះសម្រាប់សិក្ខាកាមហ្វឹកហ្វឺនជំនាញឬទេ។

**10. លើសពីនេះ ត្រូវមានជំនាញដែលចាំបាច់សម្រាប់បញ្ជូនពាក្យសុំរបស់សិក្ខាកាមហ្វឹកហ្វឺន ជំនាញទៅក្រុមហ៊ុនទទួលបន្ទុកគ្រប់គ្រងឱ្យបានត្រឹមត្រូវ។**

☐ តើការអប់រំមុនការមកដល់ប្រទេសជប៉ុនដែលក្រុមហ៊ុនបញ្ជូនបានអនុវត្តនោះ មានខ្លឹមសារសមស្របឬទេ?

✔ សូមបញ្ជាក់ជាមួយក្រុមហ៊ុនបញ្ជូនលើចំណុចដូចខាងក្រោម។

- ជាក់ស្តែង តើការអប់រំមុនចូលរៀនធ្វើឡើងដោយរបៀបណា?
- តើកម្មវិធីសិក្សាមុនចូលមកប្រទេសជប៉ុនមានអ្វីខ្លះ?
- តើក្រុមហ៊ុនបានកែឆ្នៃយ៉ាងដូចម្តេចខ្លះដើម្បីការអប់រំប្រកបដោយប្រសិទ្ធិភាព?
- តើសិក្ខាកាមអាចរៀនភាសាជប៉ុនបានដល់កម្រិតណា?
- តើមានគ្រូភាសាជប៉ុនដែលមានសញ្ញាបត្រជាគ្រូឬទេ?
- តើក្រុមហ៊ុនផ្តល់ព័ត៌មានត្រឹមត្រូវអំពីជំនាញភាសាជប៉ុនរបស់សិក្ខាកាមដែលត្រូវបញ្ជូនដែរឬទេ?
- តើការចំណាយសមស្របនឹងខ្លឹមសារនៃការអប់រំដែរឬទេ?

※ សិក្ខាកាមហ្វឹកហ្វឺនជំនាញដែលបានទទួលការអប់រំនៅក្រុមហ៊ុនបញ្ជូនដែលមានការអប់រំមុនការមកដល់ប្រទេសជប៉ុនបានគ្រប់គ្រាន់ នឹងអាចចាប់ផ្តើមការហ្វឹកហ្វឺនផ្នែកបច្ចេកទេសដោយរលូន ព្រោះមិនសូវមានគម្លាតវប្បធម៌ និងភាសាខ្លាំងពេកបន្ទាប់ពីចូលមកប្រទេសជប៉ុន។

# ចំណុចសម្គាល់សម្រាប់ការជ្រើសរើសក្រុមហ៊ុនបញ្ជូនសិក្ខាកាមនៅបរទេស

☐ តើក្រុមហ៊ុនបានគាំពារដល់សិក្ខាកាមហ្វឹកហ្វឺនជំនាញ បានត្រឹមត្រូវឬទេក្នុងអំឡុងពេលកម្មសិក្សារបស់ពួកគេ?

✔ ពិនិត្យជាមួយក្រុមហ៊ុនទទួលបន្ទុកគ្រប់គ្រងដើម្បីបញ្ជាក់ថាតើមានការត្រៀមដើម្បីឆ្លើយតបអោយបានទាន់ពេលវេលាចំពោះការសាកសួរពីសិក្ខាកាមហ្វឹកហ្វឺនជំនាញដែរឬទេ។

✔ បញ្ជាក់ថាក្រុមហ៊ុនបានបង្កើតប្រព័ន្ធសម្រាប់ទាក់ទង និងពិភាក្សាជាមួយក្រុមហ៊ុនទទួលបន្ទុកគ្រប់គ្រង ក្នុងករណីមានសិក្ខាកាមហ្វឹកហ្វឺនជំនាញជួបបញ្ហាណាមួយ។

※ ប្រសិនបើក្រុមហ៊ុនបញ្ជូនមានអ្នកតំណាងនៅប្រទេសជប៉ុន ដូចជាការិយាល័យតំណាង ឬការិយាល័យសាខានៅប្រទេសជប៉ុន ពួកគាត់អាចទៅជួបសិក្ខាកាមហ្វឹកហ្វឺនជំនាញឱ្យបានទៀងទាត់ ឬឆាប់រហ័សក្នុងករណីមានបញ្ហាកើតឡើង។

## ឧទាហរណ៍នៃយន្តការរបស់ក្រុមហ៊ុនបញ្ជូន

〔ឧទាហរណ៍ទី 1〕

សម្រាប់ការអប់រំមុនការមកដល់ប្រទេសជប៉ុន និងការអប់រំសម្រាប់ការរៀបចំផែនការអាជីព សូមប្រើប្រាស់ព័ត៌មានការងារជាក់ស្តែងនៅក្នុងប្រទេសបញ្ជូន ដើម្បីអោយពួកគាត់អាចយល់បានថានឹងមានប្រាក់ចំណូលខុសគ្នាបន្ទាប់ពីត្រឡប់មកប្រទេសកំណើតវិញ (~ អាយុចូលនិវត្តន៍) អាស្រ័យលើភាពខុសគ្នានៃជម្រើសកន្លែងការងារដែលទទួលបានតាមរយៈការប្រឡងតេស្តសមត្ថភាពភាសាជប៉ុន។ លទ្ធផលនៃការអប់រំអំពីផែនការអាជីពនេះ អាចធ្វើអោយសមត្ថភាពភាសាជប៉ុនរបស់សិក្ខាកាមមានភាពប្រសើរឡើងក្រោយពីបានចូលមកប្រទេសជប៉ុ ហើយសិក្ខាកាមហ្វឹកហ្វឺនជំនាញមួយចំនួនបានប្រឡងជាប់ N3 ក្នុងរយៈពេលកន្លះឆ្នាំបន្ទាប់ពីចូលប្រទេសជប៉ុន។

លើសពីនេះ ក្រុមហ៊ុនបានធ្វើការអប់រំផ្សេងទៀតមុនចូលប្រទេសជប៉ុន ដូចជាក្រុមហ៊ុនបានរៀបចំធ្វើករណីសិក្សាជាក់ស្តែងសម្រាប់សិក្ខាកាម ដែលអាចលើកទឹកចិត្តឱ្យបេក្ខជនសិក្ខាកាមហ្វឹកហ្វឺនជំនាញគិតដោយខ្លួនឯងដោយផ្អែកលើឧទាហរណ៍ជាក់ស្តែងនោះ និងការពារបញ្ហាដែលអាចកើតមានឡើងជាមុន។ ឧទាហរណ៍សម្រាប់បេក្ខជនសិក្ខាកាមហ្វឹកហ្វឺនជំនាញ ដែលគ្រោងនឹងចូលរួមវគ្គហ្វឹកហ្វឺនជាក់ស្តែងក្នុងឧស្សាហកម្មផលិតចំណីអាហារ ប្រសិនបើពួកគេពាក់គ្រឿងអលង្ការនៅក្នុងកន្លែងធ្វើការ នោះវាអាចធ្វើអោយមានការលាយឡំនូវសារធាតុមិនត្រឹមត្រូវ និងហានិភ័យក្នុងករណីមិនគោរពតាមច្បាប់ទម្លាប់នៅក្នុងកន្លែងការងារជាដើម។

〔ឧទាហរណ៍ទី 2〕

នៅពេលសិក្ខាកាមហ្វឹកហ្វឺនជំនាញត្រឡប់មកប្រទេសកំណើតវិញ អោយពួកគាត់ធ្វើជាគ្រូបង្រៀនដល់បេក្ខជនសិក្ខាកាមដែលត្រៀមចេញមកប្រទេសជប៉ុន ដើម្បីណែនាំឧទាហរណ៍នៃវគ្គហ្វឹកហ្វឺនបច្ចេកទេសនៅកន្លែងហ្វឹកហ្វឺនបច្ចេកទេស និងដឹកនាំជំនាញកសិកម្មនៅកសិដ្ឋានពិសោធន៍ជាដើម។ ធ្វើបែបនេះ អាចធ្វើអោយបេក្ខជនសិក្ខាកាមហ្វឹកហ្វឺនជំនាញចាប់ផ្តើមការហ្វឹកហ្វឺនកសិកម្មតាមបែបជប៉ុនបានរលូនបន្ទាប់ពីមកដល់ប្រទេសជប៉ុន។ ម្យ៉ាងទៀត តាមរយៈការបើកថ្នាក់ភាសាជប៉ុនយ៉ាងតិចប្រាំមួយខែ យើងអាចឱ្យសិក្ខាកាមហ្វឹកហ្វឺនជំនាញមកប្រទេសជប៉ុននៅកម្រិតភាសាជប៉ុន N4 ឬ N5។

# ចំណុចសម្គាល់សម្រាប់ការជ្រើសរើសក្រុមហ៊ុនបញ្ជូនសិក្ខាកាមនៅបរទេស

## ឧទាហរណ៍នៃយន្តការរបស់ក្រុមហ៊ុនបញ្ជូន

〔ឧទាហរណ៍ទី 3 〕

រៀបចំប្រព័ន្ធទំនាក់ទំនងដើម្បីឱ្យសិក្ខាកាមហ្វឹកហ្វឺនជំនាញអាចទាក់ទងអ្នកចាំប្រឹក្សាជំនួយនៅក្រុមហ៊ុនបញ្ជូន ឬបុគ្គលិកនៅការិយាល័យទំនាក់ទំនងនៃប្រទេសជប៉ុន។ បង្កើតទំនាក់ទំនងជិតស្និទ្ធ និងកសាងទំនាក់ទំនងនៃការជឿទុកចិត្តរវាងសិក្ខាកាមហ្វឹកហ្វឺនជំនាញ បុគ្គលិកនៃក្រុមហ៊ុនបញ្ជូន និងការិយាល័យរបស់ក្រុមហ៊ុនបញ្ជូនរបស់ប្រទេសជប៉ុនតាំងពីពេលមុនចូលប្រទេសជប៉ុន។ តាមរយៈការធ្វើដូច្នេះ វាអាចធ្វើ
អោយមានបរិយាកាស និងប្រព័ន្ធដែលផ្តល់ភាពងាយស្រួលដល់សិក្ខាកាមក្នុងការទាក់ទងបុគ្គលិករបស់ក្រុមហ៊ុនបញ្ជូន មិនចំពោះត្រឹមតែរឿងការងារប៉ុណ្ណោះទេ ថែមទាំងសម្រាប់កិច្ចការនានាប្រចាំថ្ងៃផងដែរ។ តាមរយៈការបង្កើតបរិយាកាសងាយស្រួលដល់សិក្ខាកាមហ្វឹកហ្វឺនជំនាញក្នុងការបង្ហាញពីអារម្មណ៍ពិតរបស់ពួកគេចំពោះបុគ្គលិកនៅក្នុងក្រុមហ៊ុនបញ្ជូន ពួកគេអាចប្រឹក្សាជាមួយបុគ្គលិកក្រុមហ៊ុនបាន ទោះបីជាបញ្ហាតូចតាចក៏ដោយ ដែលវាអាចការពារមិនឲ្យបញ្ហាធំកើតឡើងភ្លាមៗនៅថ្ងៃណាមួយ។

ម៉្យាងទៀត តាមរយៈការយល់ដឹងអំពីឥរិយាបថជីវិត និងបុគ្គលិកលក្ខណៈរបស់សិក្ខាកាមហ្វឹកហ្វឺនជំនាញ នៅក្នុងអំឡុងពេលពួកគេទទួលការហ្វឹកហ្វឺននៅក្នុងក្រុមហ៊ុនបញ្ជូន និងជូនដំណឹងទៅក្រុមហ៊ុនដែលជាទីកន្លែងហ្វឹកហ្វឺនអំពីរឿងទាំងនោះជាមុន ដើម្បីអ្នកដឹកនាំការហ្វឹកហ្វឺនបច្ចេកទេសបានដឹងពីលក្ខណៈរបស់សិក្ខាកាមហ្វឹកហ្វឺនជំនាញ និងផ្តល់ការណែនាំអំពីការងារដែលសមស្របនឹងបុគ្គលិកលក្ខណៈរបស់ពួកគេ។

លើសពីនេះ នៅពេលសិក្ខាកាមហ្វឹកហ្វឺនជំនាញមានបញ្ហា ក្រុមហ៊ុនបញ្ជូនឆ្លើយតបជាលក្ខណៈបុគ្គល និងគាំទ្រដល់សិក្ខាកាមហ្វឹកហ្វឺនជំនាញទាំងនោះ។ នៅពេលសិក្ខាកាមហ្វឹកហ្វឺនជំនាញត្រូវចូលសម្រាកព្យាបាលនៅមន្ទីរពេទ្យ ការិយាល័យរបស់ក្រុមហ៊ុនបញ្ជូននៅប្រទេស
ជប៉ុនចុះសួរសុខទុក្ខសិក្ខាកាមដល់មន្ទីរពេទ្យ ហើយក្រុមហ៊ុនបញ្ជូនជាអ្នកជួយទំនាក់ទំនងទៅក្រុមគ្រួសាររបស់សិក្ខាកាមហ្វឹកហ្វឺនជំនាញ រាយការណ៍អំពីស្ថានភាពសម្រាកព្យាបាលនៅមន្ទីរពេទ្យ ហើយជួយសម្រួលកង្វល់របស់សិក្ខាកាមហ្វឹកហ្វឺនជំនាញ និងក្រុមគ្រួសាររបស់ ពួកគាត់។

〔ឧទាហរណ៍ទី 4 〕

ការិយាល័យរបស់ក្រុមហ៊ុនបញ្ជូននៅប្រទេសជប៉ុន បង្កើតប្រព័ន្ធមួយដែលអនុញ្ញាតឱ្យពួកគេអាចទាក់ទងជាមួយសិក្ខាកាមកម្មសិក្សាបច្ចេកទេសទាំងអស់ និងក្រុមគ្រួសាររបស់ពួកគេ ក្រុមហ៊ុនអនុវត្តការហ្វឹកហ្វឺន និងក្រុមហ៊ុនទទួលបន្ទុកគ្រប់គ្រង គ្រប់ពេលវេលា។ ពួកគេរក្សាទំនាក់ទំនងជិតស្និទ្ធជាមួយក្រុមគ្រួសារ ដូចជាការជួបមុខគ្នាមុនពេលសិក្ខាកាមចាកចេញទៅប្រទេសជប៉ុន។ ក្រុមហ៊ុនព្យាយាមរក្សាទំនាក់ទំនងជិតស្និទ្ធជាមួយសិក្ខាកាមហ្វឹកហ្វឺនជំនាញ ដើម្បីជួយពួកគេនៅពេលពួកគេមានអារម្មណ៍ថប់ឬបារម្ភ ដូចជាពេលទើបចូលមកប្រទេសជប៉ុនភ្លាមៗ មុនពេលចាប់ផ្តើមការហ្វឹកហ្វឺន រយៈពេលប្រហែល មួយខែបន្ទាប់ពីចាប់ផ្តើមការហ្វឹកហ្វឺន និងមុនពេលប្រឡងឡើងឆ្នាំ ដើម្បីអោយសិក្ខាកាមហ្វឹកហ្វឺនជំនាញមានអារម្មណ៍ថា “ពួកគេមិនមែននៅតែឯងទេ” និងមានអារម្មណ៍ស្ងប់ចិត្ត អាចផ្តោតលើការហ្វឹកហ្វឺនជាក់ស្តែង។ ជាមួយគ្នានេះ ក្នុងករណីមានគ្រោះមហន្តរាយ និយោជិតជប៉ុនដែលអាចនិយាយបានទាំងភាសាជប៉ុន និងភាសាកំណើតរបស់សិក្ខាកាម អាចផ្តល់ព័ត៌មានជាក់លាក់បាន។

< ប្រព័ន្ធតាមដានក្នុងករណីមានគ្រោះមហន្តរាយ >

① ការបញ្ជាក់អំពីសុវត្ថិភាពរបស់សិក្ខាកាមហ្វឹកហ្វឺនជំនាញ

② ការចែករំលែកព័ត៌មាននៅលើបណ្តាញទំនាក់ទំនងសង្គម ផ្ទៃក្នុងរបស់ក្រុមហ៊ុនបញ្ជូន

③ រាយការណ៍ពីសុវត្ថិភាពរបស់សិក្ខាកាមហ្វឹកហ្វឺនជំនាញជូនទៅគ្រួសាររបស់គាត់នៅក្នុងប្រទេសកំណើត។